# មេរៀនទី ១៤៣៖ យ៉ូសាផាតទុកចិត្តព្រះដើម្បីជ័យជំនះ

២ របាក្សត្រ ២០៖ ១-៣០

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/zlB1-tnhltk

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ**៖ https://youtu.be/j60VSPUsqZc

**គោលបំណង**៖ ព្រះជួយដល់យើងពេលយើងជួបបញ្ហា។

**ខគម្ពីរចងចាំ**៖ ទំនុកដំកើង ១២១៖២ *"សេចក្តីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេ គឺជាព្រះដែលបង្កើតផ្ទៃមេឃ និងផែនដី។"*

**ចំរៀង** ( *យូធូបលីង* )៖

១. One Way https://youtu.be/UB2IpeVHaOM

២. ខ្ញុំរត់ពីព្រះជាម្ចាស់មិនបាន https://youtu.be/e3O9GqwVGCk

៣. ហូសាណា https://youtu.be/QWQ47zCVaCw

## ១. អធិស្ឋាន

## ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

## ៣. ល្បែងកំសាន្ត «រើសសំរាម!»

សម្ភារៈដែលត្រូវការ៖ ធុងសំរាម ថង់ប្លាស្ទិក (ក្រដាសខ្ទិកខ្ទុក ដបទឹកទទេ និងរបស់ផ្សេងៗទៀត)



១. ទុកសំរាមនៅគ្រប់កន្លែងផ្សេងៗនៅក្នុងថ្នាក់រៀន។

២. ចែកកុមារជា ២ ក្រុម។

៣. សុំឱ្យក្រុមនីមួយៗបញ្ជូនអ្នកតំណាងម្នាក់។ ប្រាប់អ្នកតំណាងទាំង ២ នាក់ឱ្យរើសសំរាមឱ្យបានច្រើនតាម ដែលអាចធ្វើទៅបានដោយប្រើតែ ដៃម្ខាងតែប៉ុណ្ណោះ។ កុមារដែលរើសសំរាមបានច្រើនជាគេនឹងឈ្នះល្បែងនេះ។

៤. បន្ទាប់មក អនុញ្ញាតឱ្យក្រុមបញ្ជូនអ្នកតំណាងម្នាក់ទៀត។ ឥឡូវនេះ កុមារ ២ នាក់មកពីក្រុមនីមួយៗ អាចរើសសំរាមបានច្រើនតាមតែអាចធ្វើទៅបានដោយគ្រាន់តែប្រើតែដៃម្ខាងតែប៉ុណ្ណោះ។ ក្រុមដែលមានសំរាមច្រើនឈ្នះការប្រកួត។



៥. បន្ទាប់មកអនុញ្ញាតឱ្យអ្នកផ្សេងចូលរួមក្នុងក្រុមរើសសំរាម។ លើកនេះឲ្យថង់ប្លាស្ទិកទៅគេ។ ប៉ុន្តែពួកគេនៅ តែអាចប្រើបានតែដៃម្ខាងតែប៉ុណ្ណោះ។ ក្រុមដែលមានសំរាមច្រើនឈ្នះការប្រកួត។ (គន្លឹះ៖ កុំប្រាប់កុមារថាមនុស្សពីរនាក់អាចជួយកាន់ថង់ដោយដៃម្ខាងរបស់ពួកគេ ហើយអ្នកទីបីរើស សំរាមដើម្បីដាក់ក្នុងថង់។ )

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ពេលយើងត្រូវការជំនួយក្នុងជីវិត ព្រះតែងតែជួយយើង។

## ៤. ការណែនាំមេរៀន

តើអ្នកនឹងធ្វើយ៉ាងណាប្រសិនបើអ្នកឮថាមានកងទ័ពធំមកបំផ្លាញអ្នក? តើអ្នកនឹងលាក់ខ្លួននៅក្នុងផ្ទះ

របស់អ្នកឬ? តើអ្នកនឹងរត់គេចទេ? តើអ្នកនឹងសុំជំនួយពីឪពុកម្តាយរបស់អ្នកទេ? ថ្ងៃនេះយើងនឹងរៀនអំពីបុរសម្នាក់ដែលមានកងទ័ពដ៏ធំចូលមកបំផ្លាញគាត់ និងប្រទេសរបស់គាត់។ តោះមកដឹងពីអ្វីដែលគាត់បានធ្វើ ដើម្បីជំនះបញ្ហារបស់គាត់!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

រឿងនៅក្នុងព្រះគម្ពីររបស់យើងប្រាប់យើងអំពីបុរសម្នាក់ឈ្មោះយ៉ូសាផាត។ ទ្រង់ជាស្តេចនៃរាជាណាចក្រយូដា។ យ៉ូសាផាតស្រឡាញ់ព្រះ ហើយបានជួយរាស្ត្រទ្រង់បម្រើព្រះ។ នៅថ្ងៃមួយ យ៉ូសាផាតបានដឹងថាកងទ័ពដ៏ធំមួយកំពុងមកបំផ្លាញលោក។ តើអ្នកនឹងធ្វើយ៉ាងណាពេលអ្នក ដឹងថាមានកងទ័ពដ៏ធំមួយកំពុងមកបំផ្លាញអ្នកនោះ? ទោះជាគាត់មានទ័ពធំក៏ដោយ ក៏យ៉ូសាផាតមិនបានប្រមូលទ័ពរបស់គាត់សម្រាប់ចំបាំងដ៏ធំនេះទេ។

យ៉ូសាផាតបានដឹងថាព្រះនឹងជួយគាត់ ដូច្នេះគាត់បានអធិស្ឋានទៅព្រះ។ មនុស្សទាំងអស់បានចូលរួមដើម្បីអធិស្ឋានជាមួយគាត់ផងដែរ។ មនុស្សទាំងអស់បានតមអាហារ។ នោះមានន័យថាពួកគេមិនញ៉ាំអីទេ។ ពួកគេបានចំណាយពេលអធិស្ឋានជំនួសវិញ។ ពេលនោះ មានបុរសម្នាក់ជាមនុស្សរបស់ព្រះក្រោកឡើងហើយនិយាយថា៖ ២ របាក្សត្រ ២០៖១៥,១៧ "កុំឲ្យភ័យខ្លាចអ្វីឡើយ ក៏កុំឲ្យស្រយុតចិត្តដោយព្រោះពួកកងទ័ពធំទាំងនេះដែរ ដ្បិតចំបាំងនេះមិនមែនស្រេចនៅអ្នករាល់គ្នាទេ គឺស្រេចនៅព្រះវិញ... ចូរនៅកន្លែងរបស់អ្នក..."។ "ចូរនៅកន្លែងរបស់អ្នក" មានន័យថាឈរនៅ កន្លែងត្រឹមត្រូវសម្រាប់ការប្រយុទ្ធ។

យ៉ូសាផាតបានស្តាប់បង្គាប់។ គាត់បានសុំឱ្យអ្នកចំរៀងច្រៀងសរសើរតម្កើងព្រះជាម្ចាស់។ បន្ទាប់មកខ្មាំងសត្រូវចាប់ផ្តើមវាយគ្នាទៅវិញទៅមក ជាជាងច្បាំងនឹងទ័ពរបស់យ៉ូសាផាត! កងទ័ពរបស់យ៉ូសាផាតមិនចាំបាច់ច្បាំងទាល់តែសោះ—ដូចព្រះបានមានបន្ទូល! ព្រះបានសង្គ្រោះយ៉ូសាផាត និងរាស្ត្ររបស់ទ្រង់ពីទុក្ខលំបាករបស់ពួកគេ!

ដូចគ្នាដែរ ព្រះតែងតែចង់ជួយយើងពេលយើងមានបញ្ហា។ ព្រះយកចិត្តទុកដាក់ចំពោះបញ្ហានីមួយៗដែលយើងមាន។ ព្រះយកចិត្តទុកដាក់ពេលយើងភ័យខ្លាច ហើយទ្រង់លួងលោមយើង។ ព្រះយកចិត្តទុកដាក់នៅពេលដែលយើងវង្វេង ហើយទ្រង់ផ្តល់ប្រាជ្ញា និងការយល់ដឹង។ មិនថាបញ្ហារបស់យើងធំឬតូចប៉ុណ្ណានោះទេ យើងអាចជឿជាក់បានថា ព្រះមិនត្រឹមតែយកព្រះទ័យទុកដាក់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់នឹងផ្តល់ជំនួយដ៏ត្រឹមត្រូវ ដើម្បីឲ្យយើងឆ្លងកាត់វាបាន។ យើងមានព្រះដ៏អស្ចារ្យដែលតែងតែជួយយើង!

## ៦. សំនួរពិភាក្សា

១. តើរឿងក្នុងព្រះគម្ពីររបស់យើងថ្ងៃនេះស្តេចយូដាមានឈ្មោះអ្វី? *(យ៉ូសាផាត)*

២. តើគាត់បានធ្វើអ្វីពេលគាត់ឮថាមានកងទ័ពដ៏ធំមួយកំពុងមកបំផ្លាញស្រុកយូដា?
*(គាត់បានអធិស្ឋានសុំជំនួយពីព្រះ)*
៣. តើព្រះបានជួយយ៉ូសាផាតឲ្យឈ្នះការច្បាំងយ៉ាងណា ពេលគាត់ស្តាប់បង្គាប់ព្រះ?
*(ពួកខ្មាំង សត្រូវវាយគ្នាឯងជំនួសឲ្យការវាយទ័ពរបស់យ៉ូសាផាត)*
៤. តើអ្នកអាចធ្វើអ្វីបាននៅពេលអ្នកមានបញ្ហា ឬជួបទុក្ខលំបាក? *(អ្នកអាចសុំជំនួយពីព្រះ)*

## ៧. ល្បែងកំសាន្ត «ព្រះជួយយើង»

១. ជ្រើសរើសកុមារ ២ នាក់ ដែលម្នាក់ដើរតួជា "បញ្ហា" និង ម្នាក់ទៀតជា "អ្នកជួយ"

២. កុមារដែលនៅសល់ត្រូវតែរត់ចេញពី "បញ្ហា" ហើយ "បញ្ហា"ត្រូវតែព្យាយាមទៅប៉ះកុមារទាំងអស់នោះ។




៣. នៅពេលដែល "បញ្ហា" ប៉ះកុមារបាន ពួកគេត្រូវតែឈប់ទ្រឹង មួយកន្លែង។ បន្ទាប់មក ពួកគេអាចសុំឱ្យ "អ្នកជួយ" មកជួយប៉ះពួកគេ ដើម្បីឲ្យពួកគេអាចរត់បន្ត។

៤. “អ្នកជួយ” ត្រូវតែរត់ជុំវិញដើម្បីស្វែងរកអ្នកដែលស្កុបមួយកន្លែង ហើយប៉ះពួកគេដើម្បីឲ្យពួកគេរត់បន្ត វិញ។

៥. បន្ទាប់ពីលេងល្បែងនេះបានប្រហែល ៥ នាទី សូមជ្រើសរើសកុមារ ២ នាក់ទៀតដើម្បីធ្វើជា "អ្នកជួយ" ។ វិធីនេះមិនថា "បញ្ហា" ធ្វើឲ្យកុមារស្កុបច្រើនប៉ុណ្ណាក៏ដោយក៏មាន "អ្នកជួយ" ជាច្រើនបន្ថែមទៀតដើម្បីជួយកុមារឲ្យឈប់ទ្រឹងទាំងនោះបាន។

៦. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា ទោះបីជាបញ្ហាធំប៉ុណ្ណាក៏ដោយ ព្រះរបស់យើងធំជាង ហើយតែងតែជួយយើងពីបញ្ហារបស់យើងនោះ។

## ៨. ខគម្ពីរចងចាំ

**ទំនុកដំកើង ១២១:២** *“សេចក្តីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេ គឺជាព្រះ ដែលបង្កើតផ្ទៃមេឃ និងផែនដី។”*

## ៩. ហត្ថកម្ម

ផាត់ពណ៌រូបភាពរបស់យ៉ូសាផាត។

## ១០. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូះ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
យើងដែលជាអ្នកដើរតាមព្រះគ្រីស្ទ ជារាស្ត្រនៃនគរដ៏អស្ចារ្យរបស់ទ្រង់។ ពេលយើងប្រឈមមុខនឹងការលំបាក ព្រះយេស៊ូវនៅក្បែរយើង។ ទ្រង់ប្រទានឲ្យយើងនូវប្រាជ្ញា—និងយុទ្ធសាស្ត្រដែលនាំទៅរកជ័យជម្នះ និងសន្តិភាព។ អានការអធិស្ឋានរបស់យ៉ូសាផាតឡើងវិញនៅក្នុង ខ ៦-១២។ សូមកត់សម្គាល់ថា គាត់ប្រកាសពីអំណាចនៃព្រះ ចងចាំពីកិច្ចការរបស់ព្រះ ហើយទទួលស្គាល់ការពឹងផ្អែកលើព្រះ។ សូមពិចារណាអំពីសមរភូមិក្នុងជីវិតរបស់អ្នក ហើយសរសេរការអធិស្ឋានស្រដៀងគ្នានៃការសរសើរ និងការទទួចអង្វរទៅកាន់ព្រះ។

# យ៉ូសាផាតទុកចិត្តព្រះដើម្បីជ័យជំនះ



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________

______________________________________________

______________________________________________